# ប្រព័ន្ធកសិកម្មចម្រុះ រវាងការចិញ្ចឹមគោ ការធ្វើស្រែ
# សណ្តែកបាយ ត្រសក់ និងត្រកួន

## ១. និយមន័យ

ប្រព័ន្ធកសិកម្មចម្រុះ **រវាងការចិញ្ចឹមគោ ការធ្វើស្រែ សណ្តែកបាយ ត្រសក់ និងត្រកួន** គឺជាការធ្វើកសិកម្មដែលមានអន្តរអំពើឲ្យគ្នាទៅវិញទៅមក និងជាពិសេសបានផលចំណេញដល់កសិករយ៉ាងខ្លាំង។ ពិព្រោះថាការចិញ្ចឹមគោ អាចយកលាមកមកធ្វើជាជីដាក់ស្រែ ដាក់ត្រកួន និងដំណាំផ្សេងទៀត។ ការដាំសណ្តែកបាយ វាបានបង្កើនគុណភាពដី ជីជាតិដី និងស្មៅសម្រាប់ទុកឲ្យគោស៊ីផងដែរ។ ការធ្វើស្រែ វាបានផលសម្រាប់ផលិតជាអង្ករ កន្ទក់ ក៏ដូចជាចំបើងទុកឲ្យគោស៊ី ជាពិសេសជញ្ជ្រាំងទុកសម្រាប់គ្របដី គ្របរងដំណាំ ដូចជា ត្រកួន ត្រសក់ ជាដើម ហើយជាពិសេស ការមានប្រព័ន្ធកសិមកម្មបែបនេះក្នុងគ្រួសារ វាបានបង្កភាពងាយស្រួស និងកំណើនសេដ្ឋកិច្ចដល់គ្រួសារ។




## ២. ការរៀបចំប្លង់

តាមរយៈការសិក្សា និងការចុះសង្កេតជាមួយកសិករឃើញថា ការអនុវត្តន៍ប្រព័ន្ធកសិកម្មចម្រុះ បែបនេះមាប្រមាណ ១០ ភាគរយដែលអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។

ជាទូទៅនៅក្នុងភូមិមាន ១០៦ គ្រួសារ ហើយមានគ្រួសារប្រមាណ ១០ គ្រួសារដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ធាតុសំខាន់នៃប្រព័ន្ធនេះរួមមាន ការចិញ្ចឹមសត្វ ការធ្វើស្រែ និងការដាំបន្លែ និងជាពិសេសប្រព័ន្ធទឹក។

- ❖ ទំហំដីលំនៅដ្ឋានមានចាប់ពី ៣០០ ម៉ែត្រការ៉េឡើងទៅ រហូតដល់ដល់ ២ ហិចតាដែលបានអនុវត្តន៍ប្រព័ន្ធកសិកម្មបែបនេះ។ ពួកគាត់បានអនុត្តន៍ប្រព័ន្ធកសិកម្មបែបនេះដើម្បីផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ និងលក់ទៅទីផ្សារខាងក្រៅ
- ❖ គោ គេចាប់ចិញ្ចឹមចាប់ពី ២ក្បាល រហូតដល់ ១៥ ក្បាល ដោយចិញ្ចឹមគោមានទីផ្សារល្អ នៅតំបន់នេះមានតម្លៃខ្ពស់គួរសម អាចលក់ និងជួយផ្គត់ផ្គង់ដល់ជីវភាពក្នុងគ្រួសារ ហើយជាពិសេសលាមកវាអាចធ្វើជាជីដាក់ដំណាំផ្សេងៗ និងកាត់បន្ថយការទិញជីគីមីផងដែរ



- ❖ ត្រសក់ មានកសិករនិយមដាំច្រើនជាងគេ ដែលមានផ្ទៃដាំចាប់ពី ២០០ ម៉ែត្រការ៉េ រហូតដល់ ៥០០ ម៉ែត្រការ៉េ។ វាជាប្រដំណាំដែលមានអាយុខ្លី ទិន្នផលច្រើន ដាំបានទាំងខែប្រាំង និងវស្សាហ៍ ដែលមានតម្លៃទីផ្សារខ្ពស់ និងងាយស្រួលលក់ ដែលអាចឲ្យប្រជាកសិករមួយចំនួនអាចរកប្រាក់ចំនូលបានច្រើនពីវា ក្នុងមួយថ្ងៃចន្លោះពី ៥០ គីឡូ ទៅ ១០០ គីឡូក្រាមក្នុមួយថ្ងៃប៉ុន្តែចាំបាច់កសិករត្រូវចេះបច្ចេកទេស និងមានប្រព័ន្ធទឹកស្រោចស្រប់គ្រប់គ្រាន់



- ❖ ត្រកួន មានទំហំចាប់ពី ៥០ ម៉ែត្រការ៉េ រហូតដល់ ២០០ ម៉ែត្រការ៉េ វាជា ប្រភេទដំណាំដែលធន់នឹងអាកាសធាតុ អាចដាំបានគ្រប់រដូវ ប៉ុន្តែត្រូវការទឹកច្រើននៅ រដូវប្រាំង។

ដំណាំត្រកួនងាយស្រួលដាំ ឆាប់បានផល និងអាចផ្គត់ផ្គង់ សម្រាប់ក្នុង គ្រួសារ និងលក់ទៅកាន់ទីផ្សារខាងក្រៅ។ ដំណាំនេះ វាមានផលប្រយោជន៍ ដល់មនុស្ស និងសត្វធ្វើជាអាហារ

- ការធ្វើស្រែ មានផ្ទៃដីចាប់ពី ០.៤០ ទៅ ៣ ហិចតាចាប់ពីខែ មេសា និង ឧសភា និងប្រមូលផល ខែ វិច្ឆិកា ដល់ ធ្នូ ហើយទទួលផលបានក្នុង១ហិចតាចន្លោះពី ១.៥ តោន ទៅ ៣ ទៅតាមពូជ ទឹក និងគុណភាពដីជាតិដី។





## ៣. គុណសម្បត្តិ

ប្រព័ន្ធកសិកម្មនេះ គឺវាអាចធន់នឹងអាកាសធាតុ និងបង្កើនជីជាតិដី ពីព្រោះ ការព្រោះសណ្តែកបាយលើផ្ទៃដីធ្វើស្រែដើម្បីធ្វើជាគម្របដី បង្កើនជីជាតិដី និងស្មៅ សម្រាប់គោស៊ី លាមកគោយកដាក់ស្រែ ដំណាំត្រកួន ត្រសក់។ វាបានបំពេញឲ្យគ្នា មិនបាច់ចាំបាច់ប្រើជីគីមីពី ខាងក្រៅ បង្កើនទិន្នផលខ្ពស់ និងជាពិសេសបង្កើនជីជាតិដី និងចំនេញផ្ទៃដីដាំដុះ។

- បង្កើនសេដ្ឋកិច្ចគ្រួសារ លក់កំលាំងពលកម្ម និងកាត់បន្ថយការចំណាកស្រុក
- បង្កើតអោយមានមីក្រូអាកាសធាតុល្អនៅក្នុងដីលំនៅដ្ឋាន មានម្លប់សម្រាប់សត្វ
- មិនទុកដីឲ្យទំនេរ ងាកមកដាំដំណាំដែលមានផលប្រយោជន៍សម្រាប់គ្រួសារ
- ងាយស្រួលក្នុងការការប្រមូលសម្រាម និងផលិតជីធម្មជាតិសម្រាប់ដាក់ដំណាំ បង្កើនជីជាតិជាតិដី កាត់បន្ថយការប្រើប្រាស់ជីគីមី
- កាត់បន្ថយការចំណាយទិញស្បៀង ( ផ្លែឈើ សាច់...) ពីទីផ្សារនិងទទួលបានប្រាក់ចំណូលពីការលក់ផលិតផលទៅទីផ្សារ។
- ផលិតផលកសិកម្មមានសុវត្ថិភាព និងគុណភាព ងាយស្រួលលក់។

## ៤. គុណវិបត្តិ

ការធ្វើប្រព័ន្ធកសិកម្មចម្រុះបែបនេះទាមទាឲ្យកសិករមានការតាំងចិត្ត ឧស្សាហ៍ព្យាយាម ពេលវេលា កំលាំងពលកម្ម សម្រាប់មើលថែគ្រប់គ្រង និងដើមទុនច្រើនសម្រាប់បង្កើតវា

- ចំណាយដើមទុនច្រើនកំលាំងពលកម្មច្រើនពេលវេលាយូរអង្វែងសម្រាប់គ្រប់គ្រងមើលថែវា
- តម្រូវការប្រើប្រាស់ទឹកច្រើនពេញមួយឆ្នាំ
- ពិបាកគ្រប់គ្រងកសិដ្ឋាន នៅពេលមានបញ្ហាសត្វល្អិតបំផ្លាញ និងជំងឺចូល
- ត្រូវការប្រើប្រាស់សម្ភារៈ និងគ្រាប់ពូជអស់ច្រើន
- ប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីអស់ច្រើន។

## ៥. អនុសាសន៍ ឬចំណុចកែលម្អ

ខាងក្រោមនេះ គឺជាអនុសាសន៍ ឬចំណុចកែលម្អ ដែលទទួលបានតាម រយៈការពិភាក្សាជាមួយកសិករ និងការចុះសង្កេតផ្ទាល់ នៅក្នុងតំបន់ គោលដៅ របស់គម្រោង SUCRA៖

- កសិករគួររៀបចំឲ្យមានប្លង់មេ សម្រាប់ការរៀបចំកសិដ្ឋានប្រព័ន្ធ កសិកម្មចម្រុះរវាងការធ្វើស្រែ ការចិញ្ចឹមត្រី ការដាំឈើហូបផ្លែ និងការចិញ្ចឹមមាន់
- កសិករត្រូវជ្រើសរើសពូជស្រូវ ដែលធន់និងការបំប្រែប្រួលអាកាសធាតុ
- បង្កើនចម្រុះភាពនៃដំណាំ រួមមានការដាំបន្លែ ដាំដើមឈើហូបផ្លែ ឈើពហុ ប្រយោជន៍ ដើម្បីបង្កើនភាពធន់ទៅនឹងការអាកាសធាតុ បង្កើនភាពធន់ទៅ នឹងជម្ងឺនិងសត្វល្អិត ក៏ដូចជា មានអាហារូបត្ថម្ភ និងឱកាសទីផ្សារ
- ជ្រើសរើសដំណាំដែលមានតម្លៃទីផ្សារ ធន់ទៅនឹងអាកាសធាតុ និងមាន អាហារូបត្ថម្ភសម្រាប់ធ្វើការដាំដុះបន្ថែម។ ចំពោះឈើហូបផ្លែ កសិករគួរដាំ បន្ថែមដូចជា ក្រូចពោធិ៍សាត់ ចេក ខ្នុរ ដូងក្រអូប ស្វាយកែវរមៀត ស្វាយខ្ចិះ ត្របែកគីឡូ។ ចំពោះដើមឈើពហុប្រយោជន៍កសិករគួរដាំដើមអង្គាញ់ កន្ធំថេត អង្គាដី សណ្តែកអង្រៃ ស្តៅ ម្រុំ បន្ថែម (ដែលអាចធ្វើចំណីសត្វ ចំណីមនុស្ស ឱសថ ជី...) ។
- បើសិនជាកសិករមានទីធ្លាសមស្រប គួរតែជីកស្រះ ឬជីកប្រព័ន្ធចង្អូរ កូន ប្រឡាយនៅជុំវិញដីលំនៅដ្ឋាន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទឹក។

៚

រៀបរៀងដោយ ៖ គម្រោងការពង្រឹកបច្ចេកទេសកសិកម្មដែលធន់នឹងអាកាសធាតុ (SUCRA) នៃកម្មវិធីASPIRE
ផលិតឆ្នាំ ៖ ២០២០